**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខ : ៤៩៩សជណ ប.ស្ក

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ៖** ករណីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សម្រាប់គម្រោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៥ (ផ្នែកខាងត្បូង) ព្រែកក្តាម-ធ្លាម្អម

**យោង** ៖
- ព្រះរាជក្រមលេខ នស.រកម ១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- លិខិតលេខ ៣០៩០ សក.នសអ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ ៥៩៧ សជណ ប.ស្ក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងបរិស្ថាន
- លិខិតលេខ ៣៩២៥ សក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- កិច្ចសន្យាការពារបរិស្ថានលេខ ៣៩២៦ សក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម រដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងបរិស្ថានឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សម្រាប់គម្រោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៥ (ផ្នែកខាងត្បូង) ចាប់ពីព្រែកក្តាម ដល់ធ្លាម្អម ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន តំណាងដោយ **ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន** ជាម្ចាស់គម្រោង។ ជាមួយគ្នានេះដែរ ម្ចាស់គម្រោងត្រូវ៖

១- គោរពច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

២- អនុវត្តទៅតាមខ្លឹមសារនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សម្រាប់គម្រោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៥ (ផ្នែកខាងត្បូង) ដែលក្រសួងបរិស្ថានបានឯកភាព

៣- គោរពកិច្ចសន្យាការពារបរិស្ថានលេខ ៣៩២៦ សក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

៤- មានការឯកភាពលើកិច្ចការពារបរិស្ថានពីក្រសួងបរិស្ថាន ក្នុងករណីមានការកែប្រែរបាយការណ៍សិក្សាសមទ្ធិលទ្ធភាព (Feasibility Study) ឬបង្កើតផ្នែកថ្មីណាមួយនៃគម្រោង ត្រូវជូនដំណឹងមកក្រសួងបរិស្ថានឱ្យបានមុន ០១ខែ។

សេចក្ដីដូចបានជម្រាបជូន សូម **ឯកឧត្តម រដ្ឋមន្ត្រី** ទទួលអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារខាងលើនេះ។

សូម **ឯកឧត្តម រដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

<u>ចម្លងជូន៖</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- សាលាខេត្តកណ្ដាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់
- មន្ទីរបរិស្ថានខេត្តកណ្ដាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់
- ឯកសារ កាលប្បវត្តិ